# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានៈសាលាពេទ្យកងយោធពលខេមរភូមិន្ទនៅជា វិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៦៧អនក្រ .បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានឃើញ អនុក្រឹត្យ លេខ ២១អនក្រ .បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៥អនក្រ .បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យ លេខ ៥៤អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៤

www.pheakdeylaw.com

## សម្រេច

**មាត្រា១ .-**

ត្រូវបានតម្លើងសាលាពេទ្យកងយោធពលខេមរភូមិន្ទ ទៅជាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ថ្នាក់ស្មើនាយកដ្ឋានស្ថិតនៅក្រោមការគ្រប់គ្រង របស់អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ នៃក្រសួងការពារជាតិ ។

**មាត្រា២ .-**

វិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ មានភារកិច្ច :

- បណ្តុះបណ្តាលថ្នាក់គិលានុប្បដ្ឋាក ឆ្មប បឋម និង មធ្យម
- វិក្រឹត្យការថ្នាក់គ្រូពេទ្យមធ្យម
- បណ្តុះបណ្តាលបន្ថែមគ្រូពេទ្យមធ្យមអោយទៅជាវេជ្ជបណ្ឌិត
- បណ្តុះបណ្តាល និងវិក្រឹត្យការមុខវិជ្ជាវេជ្ជសាស្ត្រផ្សេងៗបន្ថែមទៀត តាមតម្រូវការរបស់ក្រសួងការពារជាតិ ។

រាល់កម្មវិធីសិក្សាគ្រប់កំរិត ត្រូវមានការឯកភាពពីក្រសួងសុខាភិបាល និងក្រសួងអប់រំយុវជន និងកីឡា ។

**មាត្រា៣ .-**

វិទ្យាស្ថានដឹកនាំដោយ នាយក មួយ (០១)រូប និង នាយករងមួយ (០១)រូប ឬច្រើនរូបតាមតម្រូវការ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពចំណុះវិទ្យាស្ថាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា៤ .-**

ការបណ្តុះបណ្តាលបន្ថែមគ្រូពេទ្យមធ្យមអោយទៅជាវេជ្ជបណ្ឌិត ត្រូវជ្រើសរើសពីនាយទាហាន ដែលជាគ្រូពេទ្យមធ្យមទាំងពីរភេទ ដែលបានវិក្រឹត្យការរួច នៅសាលាពេទ្យកងយោធពលខេមរភូមិន្ទ និងនាយទាហាន ជាគ្រូពេទ្យមធ្យម យោធា ដែលបានបញ្ចប់ វគ្គសិក្សាមកពីសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ។

ចំពោះថ្នាក់គិលានុប្បដ្ឋាក ឆ្មប បឋម និង មធ្យម ត្រូវជ្រើសរើសពីនាយទាហានរង នៅតាមបណ្តាកងឯកភាពនានា ។

លក្ខខណ្ឌ និង ចំនួន នៃការជ្រើសរើស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ដោយមានការឯកភាពពីក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា៥ .-**

សិទ្ធិសំរេចនៃការចេញ សញ្ញាប័ត្រ វេជ្ជបណ្ឌិត គឺជាបន្ទុករួមរបស់ក្រសួងការពារជាតិ និង ក្រសួងអប់រំ យុវជន និង កីឡា ដោយមានការត្រួតពិនិត្យ និង វាយតម្លៃផ្នែកបច្ចេកទេសពីក្រសួងសុខាភិបាល ។

**មាត្រា៦ .-**

ក្រសួងការពារជាតិ និងក្រសួងសុខាភិបាល ត្រូវសហការធានាផ្តល់គ្រូបង្រៀន និងទីកន្លែងសំរាប់ធ្វើកម្មសិក្សា ។

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិង កីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com